**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ..០៩៩ (២៨).. ក.អ.ជ

ភ្នំពេញ, ថ្ងៃទី..២៤..ខែមិថុនា.....ឆ្នាំ200.2

# ប្រកាស

## ស្ដីពីការតែងតាំងមន្ត្រីរាជការ

### សំរាប់គំរោងឥណទានធនាគារអភិវឌ្ឍន៍អាស៊ី និងគំរោងធនាគារពិភពលោក

### រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការបង្កើតរាជរដ្ឋាភិបាលបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស /រកម /០១៩៦ /១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការប្រកាសឱ្យប្រើនូវច្បាប់ ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញ កិច្ចព្រមព្រៀងឥណទានលេខ ១៨២៤ - CAM (SF) ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ស្ដីពីគំរោងស្ដារឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធជនបទដែលខូចខាតដោយទឹកជំនន់.
- បានឃើញ កិច្ចព្រមព្រៀងឥណទានលេខ ៣៤៧២- (KH) ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០១. រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក ស្ដីពីគំរោងស្ដារឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធជនបទដែលខូចខាតដោយទឹកជំនន់ ។
- បានឃើញ សំណើតែងតាំងមន្ត្រីរាជការ លេខ ០៦២ អជប.ភព ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ របស់មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានីភ្នំពេញ.
- យោងតាមការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**ប្រការ១** : តែងតាំង លោក **ឯម សុភី** ជាប្រធានអង្គភាពអនុវត្តគំរោងរាជធានីភ្នំពេញ (PIU/PHP) ជំនួសលោក **សម ថន** ដែលបានទទួលមរណៈភាពនៅថ្ងៃទី៧ ខែមិនា ឆ្នាំ២០០២ សំរាប់គំរោងស្ដារឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលខូចខាតដោយ ទឹកជំនន់ ឥណទានលេខ ១៨២៤ - CAM (SF) និងគំរោងស្ដារឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធ ដែលខូចខាតដោយទឹកជំនន់ ឥណទានលេខ ៣៤៧២ - (KH) ។

**ប្រការ២:** រាល់សេចក្តីសំរេចណាដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣:** អគ្គនាយកដ្ឋានទាំងពីរ អគ្គាធិការដ្ឋាន ខុទ្ទកាល័យ គ្រប់នាយកដ្ឋានពាក់ព័ន្ធ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញ និងសាមីជនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

លី-ធុច

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាក្រុងភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចមានចែងក្នុងប្រការ៣
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ